Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 1

*ដេវិឌ ឆាណ្ឌល័រ*

(David Chandler)

# ប្រវត្តិសាស្ត្រខ្មែរ

បកប្រែពីភាសាអង់គ្លេសដោយ
ជិន ចន្ទា, ប្រាក់ សុណ្ណារ៉ា, ម៉ម វណ្ណារី, សេង សោត ។

*A History of Cambodia*

Translated from English by CHIN Channa, MAM Vannary, PRAK Sonnara, SENG Sot.

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 3



# សារបណ្ណ


*កថាមុខ* ៧

*កំណត់សម្គាល់នៃក្រុមអ្នកផ្ទៀងផ្ទាត់* ០

**១. សេចក្តីផ្តើម** ១១

**២. ដើមដំបូងនៃប្រវត្តិសាស្ត្រខ្មែរ** ២១

*ឥណ្ឌាភាវូបនីយកម្ម (ការទទួលអារ្យធម៌ឥណ្ឌា), ២៣*

*«ហ៊្វូណន», ២៦*

*ការគ្រប់គ្រង និងសង្គមខ្មែរក្នុងសម័យដើម, ៣៤*

**៣. រាជាធិបតេយ្យនិងសង្គម នៅសម័យអង្គរ** ៤១

*ប្រភពស្តីពីប្រវត្តិសាស្ត្រអង្គរ, ៤១*

*ព្រះបាទ ជយវរ្ម័ន ទី ២ និង ការស្ថាបនាអង្គរ, ៤៤*

*ព្រះបាទ យសោវរ្ម័ន និងស្តេចស្នងរាជ្យបន្ត, ៤៦*

*រាជាធិបតេយ្យនៅសម័យអង្គរ, ៥៦*

*ប្រាសាទអង្គរវត្ត, ៦០*

**៤. ព្រះបាទ ជ័យវរ្ម័ន ទី ៧ និងវិបត្តិក្នុងសតវត្សរ៍ទី ១៣** ៦៥

*ព្រះបាទ ជយវរ្ម័ន ទី ៧ និងរបបរាជាធិបតេយ្យបែបពុទ្ធសាសនា, ៦៦*

*ប្រាសាទទាំងឡាយដែលព្រះបាទ ជយវរ្ម័ន ទី ៧ បានទ្រង់ស្ថាបនា, ៧២*

*ពុទ្ធសាសនាថេរវាទ និងវិបត្តិនៅគ្រិស្តសតវត្សរ៍ទី ១៣, ៧៨*

*កំណត់ហេតុរបស់លោក ជីវ តាក្វាន់ អំពីអង្គរក្នុង គ.ស. ១២៩៦-១២៩៧, ៨២*

**៥. ប្រទេសកម្ពុជាសម័យក្រោយអង្គរ** ៨៩

*ការផ្លាស់រាជធានីពីអង្គរមកភ្នំពេញ, ៨៩*

*ប្រទេសកម្ពុជានៅគ្រិស្តសតវត្សរ៍ទី ១៥ និងទី ១៦, ៩៤*

*គុណតម្លៃនិងគុណសម្បត្តិ នៅប្រទេសកម្ពុជា ក្នុងសតវត្សរ៍ទី ១៧, ១០៣*

*ការជ្រៀតជ្រែករបស់យួននិងសៀម, ១០៩*

*សេចក្តីសន្និដ្ឋាន, ១១២*

**៦. រដ្ឋ សង្គម និងទំនាក់ទំនងជាមួយបរទេស ពីឆ្នាំ ១៧៩៤ ដល់ ១៨៤៨** ១១៥

*សង្គមនិងសេដ្ឋកិច្ច, ១១៦*

*មេកម្លាំងនិងការគ្រប់គ្រង, ១២០*

*ពួកឧកញ៉ា, ១២៤*

*ទំនាក់ទំនងរបស់ប្រទេសកម្ពុជាជាមួយប្រទេសយួននិងសៀម, ១៣០*

**៧. វិបត្តិនៅសតវត្សរ៍ទី ១៩** ១៣៧

*ការដាក់ការត្រួតត្រារបស់យួន, ១៣៨*

*ការធ្វើឲ្យប្រទេសកម្ពុជាក្លាយជាយួន (ឆ្នាំ ១៨៣៥-១៨៤០), ១៤៦*

*ប្រទេសកម្ពុជាទទួលបានឯករាជ្យមកវិញ, ១៥៦*

**៨. ដំណាក់កាលដំបូងនៃអាណាព្យាបាលបារាំងសែស** ១៦១

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 4



ការដាក់ «ប្រូតិកតូរ៉ាត់» (អាណាព្យាបាល) បារាំងសែសលើប្រទេសកម្ពុជា, ១៦៣
ការរឹតបន្តឹងនៃអាណានិគមកិច្ចបារាំងសែស, ១៦៧
ដើមរជ្ជកាលនៃព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ, ១៧៣

**៩. ការតបតរបស់ខ្មែរចំពោះបារាំងសែស ពីឆ្នាំ ១៩១៦ ដល់ ១៩៤៥** ១៧៩

ហេតុការណ៍នៃឆ្នាំ ១៩១៦, ១៧៩
ឃាតកម្មលើរូបលោករ៉េស៊ីដង់ បារដេស, ១៨៣
ការគ្រប់គ្រងនៃអាជ្ញាធរអាណានិគម និងបុព្វសម័យជាតិនិយម, ១៨៦
ឥទ្ធិពលនៃសង្គ្រាមលោកលើកទី ២, ១៩៣
ការកើនឡើងនៃគំនិតជាតិនិយម និងការវិលត្រឡប់មកវិញរបស់បារាំងសែស, ១៩៩

**១០. ការទទួលបានឯករាជ្យ** ២០៣

កំណើតនៃគណៈបក្សនយោបាយនានា, ២០៤
ការកើនឡើងនៃក្រុមឆ្វេងនិយម, ២០៩
ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ និងការសម្រេចបានឯករាជ្យ, ២១៦

**១១. ពីសម័យឯករាជ្យដល់សម័យសង្គ្រាមរវាងគ្នាឯង** ២២៥

ការបោះឆ្នោតជ្រើសរើសរដ្ឋសភា, ២២៥
នយោបាយរបស់សម្តេចព្រះ សីហនុ, ២៣១
ការប្រឆាំងនឹងសម្តេចព្រះ សីហនុ, ២៣៣
ការដឹកនាំរបស់សម្តេចព្រះ សីហនុ÷ តារាងដែលប្រកបដោយតុល្យភាព, ២៣៥
កំលុងឆ្នាំចុងក្រោយនៃសម័យសម្តេចព្រះ សីហនុ, ២៣៧
រដ្ឋប្រហារឆ្នាំ ១៩៧០, ២៤១
ការធ្លាក់ទ្រុឌទ្រោមសន្សឹមៗ នៃសាធារណរដ្ឋខ្មែរ, ២៤៣

**១២. បដិវត្តន៍នៅប្រទេសកម្ពុជា** ២៤៧

កម្ពុជាប្រជាធិបតេយ្យកាន់អំណាចក្នុងឆ្នាំ ១៩៧៥-១៩៧៦, ២៥០
ផែនការបួនឆ្នាំ, ២៥២
វិបត្តិក្នុងជួរបក្ស, ២៥៥
ការប្រយុទ្ធនឹងវៀតណាម, ២៥៩
កម្ពុជាប្រជាធិបតេយ្យដួលរលំ, ២៦១

**១៣. ប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៧៩** ២៦៧

សាធារណរដ្ឋប្រជាមានិតកម្ពុជា នៅដំណាក់កាលដំបូង, ២៦៨
ក្រុមប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា, ២៧២
ការដកកងទ័ពវៀតណាម, ២៧៧
សម័យអ៊ុនតាក់ និងសម័យក្រោយអ៊ុនតាក់, ២៨០
អវសានរបស់ខ្មែរក្រហម, ២៨៤
ពលប្រហារនៅឆ្នាំ ១៩៩៧, ២៨៥
សេចក្តីសន្និដ្ឋាន, ២៨៧

កំណត់ចំណាំ ២៩៣

ជំពូកទី ១, ២៩៣

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 5



*ជំពូកទី ២, ២៩៤*
*ជំពូកទី ៣, ២៩៩*
*ជំពូកទី ៤, ៣០៦*
*ជំពូកទី ៥, ៣១០*
*ជំពូកទី ៦, ៣១៦*
*ជំពូកទី ៧, ៣១៩*
*ជំពូកទី ៨, ៣២៣*
*ជំពូកទី ៩, ៣២៦*
*ជំពូកទី ១០, ៣៣១*
*ជំពូកទី ១១, ៣៣៥*
*ជំពូកទី ១២, ៣៣៧*
*ជំពូកទី ១៣, ៣៤១*

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 7



# កថាមុខ

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រដ៏យូរអង្វែង ប្រកបដោយមោទនភាព ជាទីចាប់ចិត្តផ្ដិតអារម្មណ៍យ៉ាងក្រៃលែង ។ ដោយហេតុនេះ ខ្ញុំបាទមានសេចក្ដីសោមនស្សជាពន់ប្រមាណក្នុងការសរសេរពាក្យពីរបីម៉ាត់នេះ ដើម្បីណែនាំអំពីសៀវភៅ **ប្រវត្តិសាស្ត្រខ្មែរ** ជាភាសាខ្មែរ ដែលបានបកប្រែចេញមកពីភាសាអង់គ្លេស ។

ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅឥតគណនា ចំពោះអ្នកទាំងឡាយ ដែលបានជួយជ្រោមជ្រែង ដើម្បីឲ្យគម្រោងការនេះឈានមកដល់សេចក្ដីសម្រេចបាន ។ បណ្ឌិត ហ្វីលីព្ព ប៉ីកាំ (Philippe Peycam) ក្នុងនាមជានាយកនៃមជ្ឈមណ្ឌលខេមរសិក្សា បានផ្ដើមគម្រោងការនេះនៅក្នុងឆ្នាំ ២០០១ ហើយបានស្វែងរកប្រាក់មូលនិធិពីមូលនិធិ វ៉ាន់វ៉េវ៉ឺរិន (van Waveren) នៅក្រុងញូយ៉ក ។ ក្រោយមក ស្ថានឯកអគ្គរដ្ឋទូតនៃសហរដ្ឋអាមេរិកប្រចាំក្រុងភ្នំពេញ ក៏បានមេត្តាផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមមកទៀត ។

គម្រោងការនេះក៏បានទទួលការជួយជ្រោមជ្រែងយ៉ាងកក់ក្ដៅពីអ្នកស្រីបណ្ឌិត ឡូអ៊ីស ដឺ ម៉េនីល (Lois de Menil) និងពីសំណាក់សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាលរបស់មជ្ឈមណ្ឌលខេមរសិក្សាផងដែរ ។

អ្នកស្រី គ្រីស្ទាន ឡាឡុងដ៍ (Christiane Lalonde) ក្នុងតួនាទីជាអ្នកបោះពុម្ពផ្សាយសៀវភៅនេះ បានចូលរួមក្នុងគម្រោងការនេះចាប់តាំងពីពេលដំបូង ហើយបាននាំមកនូវខន្តី ឆន្ទៈដ៏មុតមាំ និងជំនាញរបស់អ្នកស្រី ដើម្បីដឹកនាំគម្រោងការនេះឲ្យបានឈានមកដល់ត្រើយ ។

បណ្ឌិត បេង ហុង សុជាតិ ខេមរ៉ូ និងលោក ហេង សំណាង ជាអ្នកធ្វើការបកប្រែព្រាងដំបូង ។ ចំពោះអត្ថបទបកប្រែទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណដល់លោក ជិន ចន្ទា លោក ប្រាក់ សុណ្ណារ៉ា កញ្ញា ម៉ម វណ្ណារី និងលោក សេង សោត ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តម ខៀវ កាញារីទ្ធ និងឯកឧត្តម សំ ស៊ីដារ៉ារិន ដែលបានជួយអានឡើងវិញនូវជំពូកខ្លះៗ ។

ក្រៅពីវិស័យហិរញ្ញវត្ថុ ពីវិស័យបច្ចេកទេស និងក្រៅពីការបកប្រែ, សៀវភៅ **ប្រវត្តិសាស្ត្រខ្មែរ** ជាភាសាខ្មែរ មិនអាចចេញជារូបរាងបានឡើយ បើសិនណាជាគ្មានការចូលរួមចំណែកដ៏អស់ពីកម្លាំងកាយ និង កម្លាំងចិត្តពីសំណាក់បណ្ឌិត មីស្ហែល ប៊ុទ្ធី អង់តែល្ម និងលោក ថាច់ ដែត ដែលបានអានផ្ទៀងផ្ទាត់ជាច្រើនលើកច្រើនសា ព្រមទាំងបានសរសេរឡើងវិញនូវអត្ថបទបកប្រែទាំងអស់ និងពិនិត្យមើលឯកសារយោង តាំងពីដើមដល់ចប់យ៉ាងប្រិតប្រៀប និងហ្មត់ចត់បំផុតនោះ ។

ខ្ញុំបាទបានផ្ដោតអារម្មណ៍ទៅលើប្រទេសកម្ពុជាមុនដំបូងបំផុតនៅឆ្នាំ ១៩៥៨ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបាទបានជំពាក់គុណគ្រូសាស្ត្រាចារ្យ និស្សិត និងសហសេវិក ជាច្រើនរូប ព្រមទាំងមិត្តភក្ដិខ្មែរទាំងប៉ុន្មាន ដែលបានធ្វើឲ្យខ្ញុំបាទកើតមានទស្សនៈផ្ទាល់ខ្លួនអំពីអតីតកាលនៃប្រទេសកម្ពុជា ។ និយាយរួម លោកទាំងអស់នោះ ក៏បានចូលរួមមួយផ្នែកធំដោយឥតរៀបរាប់បាន ក្នុងការជួយធ្វើឲ្យសៀវភៅនេះបានសម្រេចជាស្ថាពរ ។

ដេវិឌ ឆាណ្ឌល័រ

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 8



Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 9



# កំណត់សម្គាល់នៃក្រុមអ្នកផ្ទៀងផ្ទាត់

ទោះបីជាសៀវភៅដែលប្រិយមិត្រអ្នកអានកំពុងកាន់នៅដៃ ជាលទ្ធផលនៃការខិតខំបកប្រែជាច្រើនដងច្រើនសា និងទោះជាមានការផ្ទៀងផ្ទាត់ដ៏ហ្មត់ចត់យ៉ាងណាក៏ដោយ ក៏គង់មានសេសសល់នូវកំហុស និងការផ្គាំផ្គួងពុំខាន ។ យើងខ្ញុំបានខំប្រឹងប្រែងអានឯកសារទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រខ្មែរ ដូចជា ព្រះរាជពង្សាវតារខ្មែរ ឬសៀវភៅប្រវត្តិសាស្ត្រសរសេរជាភាសាខ្មែរ ជាដើម ដើម្បីស្វែងរកនូវពាក្យពេចន៍ដែលគេធ្លាប់ប្រើតាមសម័យកាល ឬក៏ឈ្មោះរបស់បុគ្គល ។ល។ តែគួរឲ្យស្តាយ ដោយមានការដកស្រង់ខ្លះដែលយើងរកអត្ថបទដើមពុំឃើញ ឬអត្ថបទដើមនោះត្រូវបាត់បង់ទៅហើយ ធ្វើឲ្យពេលខ្លះយើងខ្ញុំត្រូវតែបកប្រែសាជាថ្មីវិញពីភាសាអង់គ្លេសមកភាសាខ្មែរ ដែលជាភាសានៃឯកសារដើម ។ រីឯការដកស្រង់ពីបទនិពន្ធជាភាសាថៃ ឬភាសាវៀតណាម យើងខ្ញុំក៏រកអត្ថបទដើមពុំបានដែរ ដូច្នេះត្រូវបកប្រែពីភាសាអង់គ្លេសវិញ ។

ម្យ៉ាងទៀត ក្នុងអត្ថបទដើមជាភាសាអង់គ្លេសនោះ ពោរពេញទៅដោយប្រយោគវែងអន្លាយ ដែលប្រមូលផ្តុំនូវព័ត៌មានផ្សេងៗ គ្នាជាច្រើន នាំឲ្យមានការផ្គាំផ្គួងនិងការភ្ញាំងភ្ញាត់ជាច្រើនក្នុងប្រយោគទាំងនេះនៅពេលប្រែជាភាសាខ្មែរ ហើយអាចធ្វើឲ្យអ្នកអានពិបាកនឹងយល់ទៅបានផង ។ បើយើងខ្ញុំប្រែសម្រួលឲ្យពីរោះពីសា ងាយអាន ងាយយល់នោះពុំបាន គឺដោយសារការខ្វះខាតនូវសមត្ថភាពនិងពេលវេលា តែយើងខ្ញុំបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីកុំឲ្យមានការបកប្រែខុសន័យដើម ។

មានរឿងមួយដែលអាចធ្វើឲ្យប្រិយមិត្រអ្នកអាន មានការងឿងឆ្ងល់ គឺការប្រើនាមជាតិសាសន៍ ។ នៅក្នុងសៀវភៅនេះ យើងខ្ញុំបានខំព្យាយាមប្រើពាក្យទាំងនោះឲ្យត្រូវតាមកាលសម័យ ។ ឧទាហរណ៍ នៅក្នុងពង្សាវតារនិងក្នុងអត្ថបទដទៃទៀត ដែលសរសេរក្នុងគ្រិស្តសតវត្សរ៍ទី ១៩ ដើមសតវត្សរ៍ទី ២០ និងសតវត្សរ៍មុនៗ ដែរ ជនជាតិដែលរស់នៅខាងកើត និងជនជាតិដែលរស់នៅខាងលិចនៃប្រទេសកម្ពុជា មានឈ្មោះថា យួន និងសៀម ពុំដែលឃើញមានប្រើឈ្មោះថា វៀតណាមនិងថៃឡើយ ខុសពីសម័យបច្ចុប្បន្ន ពីព្រោះនៅយុគសម័យទាំងនោះ ប្រទេសទាំងពីរនេះពុំទាន់មានឈ្មោះដូច្នេះឡើយ ។ សូមប្រិយមិត្រអ្នកអានមេត្តាយល់ថា ឈ្មោះជនជាតិ ដូចជា «សៀម» «យួន» «ខ្មែរ» «លាវ» «ចាម» «ជ្វា» ។ល។ ក្នុងសៀវភៅនេះ ជាពាក្យធម្មតា គឺពុំមានន័យល្អឬអាក្រក់ទេ ហើយក៏ពុំមានអត្ថន័យទ្រគោះ ឬមើលងាយឡើយ ។

បើនិយាយពីជនជាតិថៃមុនសតវត្សរ៍ទី ២០ នោះនឹងសំដៅទៅលើបណ្តាជនជាតិទាំងឡាយដែលនិយាយភាសានៅក្នុងអំបូរភាសាថៃ ដូចជា សៀម លាវ ថៃឈៀងហ្មៃ ថៃលឺ ពួកថៃនៅប្រទេសចិន ។ល។

ឧទាហរណ៍មួយទៀត សម្តេចព្រះមហាសុមេធាធិបតី ហួត តាត ដែលជាព្រះសង្ឃរាជគណៈមហានិកាយកាលពី គ.ស. ១៩៦៩ ដល់ គ.ស. ១៩៧៥, កាលលោកនៅជាព្រះគ្រូសង្ឃវិជ្ជានៅឡើយ លោកបានធ្វើដំណើរទៅពិនិត្យវត្តខ្មែរក្នុងខេត្តកូសាំងស៊ីន (កម្ពុជាក្រោម) ហើយលោកបានរាយការណ៍ពីការធ្វើដំណើរនេះនៅក្នុងទស្សនាវដ្តី **កម្ពុជសុរិយា** លេខ ៨ ដល់លេខ ១០ ពី គ.ស. ១៩២៨

Chandler for Kethya layout by Michel.qxd 5/22/2009 9:21 AM Page 10



*ដល់ គ.ស. ១៩២៩ ។ លោកបានហៅជនជាតិភាគច្រើននៅភូមិភាគកូសាំងស៊ីនថា យួនៗ ។ ម្យ៉ាង លោកជាពុទ្ធសាសនិកជនដ៏ខ្ជាប់ខ្ជួនមួយរូប ពុំមាននរណាអាចសង្ស័យបានឡើយថា លោកពុំមែនជាអ្នកប្រកាន់ពូជសាសន៍ ស្អប់ពួកបរទេស, ម្យ៉ាងទៀត លោកក៏ពុំអាចប្រើឈ្មោះដទៃទៀតបានឡើយ ពីព្រោះពាក្យថា យៀកណាម ឬ វៀតណាម មិនទាន់មានប្រើនៅទសវត្សរ៍ឆ្នាំ ១៩២០ ទាល់តែសោះ ។ ដូច្នេះ នៅក្នុងសៀវភៅនេះ ពាក្យថា យួន យៀកណាម និងវៀតណាម មានប្រើទៅតាមកាលសម័យទាំងឡាយដែលមានរៀបរាប់ក្នុងជំពូកទាំងប៉ុន្មាននេះ ។ បើប្រើពាក្យខុសកាលសម័យ នេះពុំសមនឹងអត្ថបទប្រកបដោយខ្លឹមសារជាវិទ្យាសាស្ត្រនោះឡើយ ។*

*សៀវភៅនេះជាសៀវភៅសរុប បានសង្ខេបរយៈពេលអស់ ២០០០ ឆ្នាំ ជាពេលដ៏យូរអង្វែង ។ ហេតុដូច្នេះហើយ អ្នកនិពន្ធពុំអាចរៀបរាប់ពីហេតុការណ៍ទាំងអស់ ឬពីរដ្ឋកាលទាំងអស់បាននោះឡើយ ។ ប្រសិនបើប្រិយមិត្រអ្នកអាន មានចំណាប់អារម្មណ៍ចំពោះប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ឬចំពោះយុគសម័យណាមួយ សូមមេត្តារកចំណងជើងនៃឯកសារយោងក្នុងកំណត់ចំណាំនៅខាងចុងសៀវភៅនេះ ។ បើប្រិយមិត្រអ្នកអាន ចង់ក្រេបជញ្ជក់នូវខ្លឹមសារជាខេមរភាសា សូមអានពង្សាវតារ និងរបាក្សត្រ ដែលមានចារលើសាស្ត្រា (ឬដែលគេបានបោះពុម្ពផ្សាយ) ឬអានសៀវភៅប្រវត្តិសាស្ត្រជាភាសាខ្មែរ ដូចជា* **ប្រវត្តិសាស្ត្រខ្មែរ ភាគ ១ (ពីដើមដល់ការបោះបង់ក្រុងអង្គរ)** *និង* **ប្រវត្តិសាស្ត្រខ្មែរ ភាគ ២ (ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស)** *និពន្ធដោយលោក ត្រឹង ងា បោះពុម្ពនៅភ្នំពេញក្នុង គ.ស. ១៩៧៣-១៩៧៤ ។ល។*

*នៅទីបំផុតនេះ យើងខ្ញុំសូមអភ័យទោសដល់អស់លោកអ្នក ចំពោះការខុសឆ្គងនិងការភ្លាំងភ្លាត់ទាំងឡាយ ហើយយើងខ្ញុំសង្ឃឹមថា នឹងកែលម្អសៀវភៅនេះឲ្យបានកាន់តែល្អប្រសើរឡើងក្នុងការបោះពុម្ពគ្រាក្រោយៗ ៕*